
សូមប្រយ័ត្ន!
ជនបោកប្រាស់ យករូបឯកឧត្តម បន្លំជាឯកឧត្តម
Ly Vuthy
Friends
ssage
ABOUT
FRIENDS
Write something to Ly...

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ព.ណ..................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ភ្នំពេញ, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា៖ កាលពីថ្មីៗ នេះ មានករណីឆបោកតាមបណ្តាញសង្គមហ្វេសប៊ុក បង្កឡើងដោយជនខិលខូច Ly Vuthy (ឈ្មោះក្នុងហ្វេសប៊ុក) បានបន្លំយករូបថត **ឯកឧត្តម អ៊ុក ប្រជា រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម** ដាក់ក្នុង Profile របស់ខ្លួន រួចផ្ញើសារទៅកាន់អ្នកលេងបណ្តាញសង្គមហ្វេសប៊ុកផ្សេងៗ ធ្វើការសុំខ្ចីប្រាក់ ក្រោមលេសក្លាយរបស់ខ្លួន មានបញ្ហានេះ ឬជួបបញ្ហានោះ ជាដើម។ល។

ទង្វើរបស់បុគ្គល Ly Vuthy នេះ បានបង្កឲ្យប៉ះពាល់ដល់កិត្តិយស **ឯកឧត្តម អ៊ុក ប្រជា** ដែលជាថ្នាក់ដឹកនាំរបស់ក្រសួងពាណិជ្ជកម្ម។

បច្ចុប្បន្ន ក្រសួងពាណិជ្ជកម្ម កំពុងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីកសាងពាក្យបណ្តឹង និងចាត់វិធានការណ៍ផ្លូវច្បាប់ ចំពោះបុគ្គលខិលខូចឈ្មោះ Ly Vuthy ឲ្យបានធ្ងន់ធ្ងរបំផុត ដើម្បីទប់ស្កាត់រាល់សកម្មភាពទុច្ចរិតរបស់បុគ្គលនេះ សំដៅរួមចំណែកលើកកម្ពស់នីតិរដ្ឋនៅកម្ពុជា។

អាស្រ័យហេតុនេះ សូមជម្រាបជូនសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងប្រុងប្រយ័ត្នចំពោះករណីឆបោកខាងលើ។

សូមអរគុណ!